# សេចក្តីថ្លែងការណ៍រួម
# របស់អង្គការសង្គមស៊ីវិលលើការព្រួយបារម្ភចំពោះការអនុម័តលើ
# សេចក្តីព្រាងច្បាប់ស្តីពី
# ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសេចក្តីព្រាងច្បាប់ស្តីពី
# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក
# ក្រុមប្រឹក្សាខណ្ឌ

សម្ព័ន្ធអង្គការសង្គមស៊ីវិល មានការសោកស្តាយ និងសំដែងនូវការខកចិត្តយ៉ាងខ្លាំង ដែលរាជរដ្ឋាភិបាល និងសភានៃកម្ពុជាបានអនុម័តយ៉ាងប្រញាប់ប្រញាល់បំផុតលើសេចក្តីព្រាងច្បាប់ស្តីពី “ ការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសេចក្តីព្រាងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ” បើទោះបីជាអង្គការសង្គមស៊ីវិលបានរង់ចាំអស់រយៈពេលយ៉ាងយូរដើម្បីពិភាក្សាលើ សេចក្តីព្រាងច្បាប់នេះឱ្យបានល្អិតល្អន់យ៉ាងណាក៏ដោយ ។

យើងមានការព្រួយបារម្ភថា ច្បាប់ស្តីពី
មួយគ្មានជំរើស និងគ្មានកូតាយេនឌ័រដើម្បីបង្កើនសមាជិកក្រុមប្រឹក្សាជាស្ត្រីឱ្យបានច្រើន ហើយដែលមិនអាចពង្រឹងគណនេយ្យភាពរបស់អ្នកជាប់ឆ្នោតបានទៀតផង ។

ប្រព័ន្ធបោះឆ្នោតអសកលក្នុងច្បាប់នេះបានកំណត់ថា គណបក្សនយោបាយត្រូវរៀបចំបញ្ជីបេក្ខជន រីឯអ្នកបោះឆ្នោតគឺជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាអ្នកដឹកនាំគណបក្សនយោបាយនៅមូលដ្ឋាន ។ ដំណើរការបោះឆ្នោតតម្រូវឱ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់បោះឆ្នោតជ្រើសរើសគណបក្សដែលខ្លួនពេញចិត្ត ។ គ្មានហេតុផលណាដែលថា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះអាចបោះឆ្នោតជ្រើសរើសគណបក្សផ្សេង ជាជាងបោះឆ្នោតជ្រើសរើសគណបក្សរបស់ខ្លួននោះទេ ។ ដូចនេះចំនួនអាសនៈនៃក្រុមប្រឹក្សាថ្មីនេះវាសមាមាត្រទៅនឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់គណបក្សនីមួយៗ ដែលគេអាចគណនាបានយ៉ាងងាយស្រួលដូចករណីបោះឆ្នោតព្រឹទ្ធសភាដែរ ។

សម្ព័ន្ធអង្គការសង្គមស៊ីវិលនៅតែទាមទារឱ្យពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗគន្លឹះដូចខាងក្រោមៈ

**១- ប្រព័ន្ធបោះឆ្នោតៈ**

**អនុសាសន៍**

- យកប្រព័ន្ធសមាមាត្រ ហើយបោះជាសកលដូចករណីបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ដែរ និងបន្ថែមប្រព័ន្ធចំរុះសំរាប់បញ្ជីបេក្ខជនឯករាជ្យ (មិនតាមរយៈគណបក្សនយោបាយ)។ បញ្ជីបេក្ខជនឯករាជ្យត្រូវកំណត់ក្នុងលក្ខខណ្ឌដែលមានសមាជិកជាអ្នកបោះឆ្នោតចុះហត្ថលេខាគាំទ្រ៣០០នាក់យ៉ាងតិច។

មូលហេតុ:

- ចង់ឱ្យការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ (ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុម-ប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ) ជាការបោះឆ្នោតជាសកល ដោយផ្ទាល់ពីប្រជាពលរដ្ឋដូចឃុំដែរ (ការបោះឆ្នោតអាចធ្វើតែមួយថ្ងៃជាមួយការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីចៀសវាងការចំណាយលើការបោះឆ្នោតច្រើនដង)។ ករណីនេះកំពុងអនុវត្តនៅបណ្តាប្រទេសមួយចំនួនដូចជា ឥណ្ឌូនេស៊ី ថៃ និងហ្វីលីពីនជាដើម..។
- បញ្ជីបេក្ខជនឯករាជ្យ នឹងផ្តល់ការលើកទឹកចិត្ត និងសិទ្ធិដល់ក្រុមប្រជាពលរដ្ឋ មិនមែនគណបក្សនយោបាយ ហើយជាក្រុមដែលការពារផលប្រយោជន៍ និងបញ្ហាផ្សេងៗនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមក្នុងកិច្ចអភិវឌ្ឍថ្នាក់ក្រោមថ្នាក់ជាតិ។

## ២-ប្រព័ន្ធកូតាសំរាប់យេនឌ័រជាតំនាងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

អនុសាសន៍

- ត្រូវមានតំណាងបុរស ឬស្ត្រីយ៉ាងតិច ១ភាគ ៣ នៅ គ្រប់រចនាសម្ព័ន្ធនៃក្រុមប្រឹក្សាៈ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ដូចមានបន្ថែមលក្ខខណ្ឌនៅក្នុងច្បាប់នេះ បញ្ជីគណបក្សនយោបាយ ឬ បញ្ជីបក្ខជនឯករាជ្យ ដែលត្រូវមានបេក្ខជនជាបុរស ឬ នារីយ៉ាងតិច ៤០ ភាគរយ ហើយត្រូវដាក់ឆ្លាស់គ្នាបេក្ខជនទៅតាមភេទទាំងពីរ។

មូលហេតុ:

- ឱ្យមានស្ត្រីនៅក្នុងរចនាសម្ព័ន្ធគ្រប់ក្រុមប្រឹក្សា

- ផ្តល់ឱកាសដល់ស្ត្រី ការចូលរួមក្នុងការដឹកនាំ និងអភិវឌ្ឍសហគមន៍ និងមូលដ្ឋានរបស់ពួកគេ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

- ដើម្បីសំរេចនូវគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា (CMDG)នៅឆ្នាំ២០១៥។

## ៣- មុខងារគន្លឹះនៃក្រុមប្រឹក្សា

អនុសាសន៍

- ស្វ័យភាពថវិកា (វិមជ្ឈការដើរបានទាល់តែមានធនធានថវិកាគ្រប់គ្រាន់)

- នាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌជាជំនួយការក្រុមប្រឹក្សាដូចស្មៀនឃុំ សង្កាត់ ដែរ ក្រុមប្រឹក្សាមានសិទ្ធិស្នើដោះដូរ។

- ឋានានុក្រមរដ្ឋបាល ប្រព័ន្ធគ្រប់គ្រង របបត្រួតពិនិត្យ គួរមានពីក្រុមប្រឹក្សាជាតិទៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌពីថ្នាក់ក្រោមទៅលើវិញអាចទាក់ទងក្រុមប្រឹក្សាជាតិដោយផ្ទាល់ពុំចាំបាច់ឆ្លងតាមឋានានុក្រមនេះទេ។

- សុំឱ្យមានការបែងចែកធនធានធម្មជាតិ ហិរញ្ញវត្ថុ សមត្ថកិច្ចដែនដី និងសេវាឱ្យច្បាស់លាស់រវាងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

មូលហេតុ:

- លប់បំបាត់ប្រព័ន្ធស្មុគស្មាញ
- កាត់បន្ថយអំណាចត្រួតពិនិត្យពីមហាផ្ទៃទៅឱ្យក្រុមប្រឹក្សាជាតិ

<u>ពត៌មានផ្សេងៗសូមទំនាក់ទំនង:</u>

| | | |
|---|---|---|
| ១-លោក គល់ បញ្ញា | នាយកប្រតិបត្តិខុមហ្វ្រែល | ទូរស័ព្ទ ០១២ ៩៤២ ០១៧ |
| ២-លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិចហ្វិក | ទូរស័ព្ទ ០១២ ៩៥៩ ៦៦៦ |
| ៣-កញ្ញា សេង ធារី | ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម | ទូរស័ព្ទ ០១២ ២២២ ៩៥២ |
| ៤-លោក ស្រី វណ្ណថុន | Country Director (ADD) | ទូរស័ព្ទ ០១២ ៨០៣ ៣៩៤ |
| ៥-លោក អ៊ឹម សុខធី | នាយកប្រតិបត្តិ Open Forum | ទូរស័ព្ទ ០១១ ៨៩១ ៩១០ |
| ៦-លោក យង់ គិមអេង | ប្រធានអង្គការ PDP Center | ទូរស័ព្ទ ០១៦ ៨២៨ ២១១ |
| ៧-អ្នកស្រី ប្រុក វណ្ណី | អ្នកសំរបសំរួលថ្នាក់ជាតិ UNIFEM | ទូរស័ព្ទ ០១២ ៩៣៨ ២០១ |